អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងកម្ពស់**

**ចិត្តចលភាព**

ការរីកចម្រើនរាងកាយ និងចលនា(ការបង្កើនកម្លាំង ការប្រឈមទប់ទល់ នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព)

**បុរេគណិត**

រង្វាស់រង្វាល់ (បញ្ញត្តិស្តីពីរង្វាស់រង្វាល់)

**គោលបំណង** ៖

**(ចិត្តចលភាព)** បង្ហាញពីរបៀបដើរ ឬលើសពីនេះតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** ដើម្បីឱ្យកុមារស្គាល់ពីបញ្ញត្តិកម្ពស់ ខ្ពស់ជាង និងទាបជាង។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**រយៈពេល** ៖ ១០ នាទី

**ឧបករណ៍** ៖ ត្រៀមសំណួរដែលទាក់ទងនឹងពាក្យ កម្ពស់ ខ្ពស់ជាង ទាបជាង។

**ការរៀបចំ** ៖ ជ្រើសរើសក្មេងៗឱ្យឡើងឈរបង្ហាញកម្ពស់។

**សេចក្តីណែនាំ៖**

1. ប្រាប់ក្មេងៗថា៖ ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែងកម្ពស់ជាមួយកូនៗទាំងអស់គ្នា។
2. ដំបូងឱ្យក្មេង២នាក់ឡើងឈរជិតគ្នា ។
3. បន្ទាប់សួរទៅកាន់ក្មេងៗឯទៀតថា៖ តើកូនមួយណាមានកម្ពស់ខ្ពស់ជាង?។
4. ជ្រើសរើសក្មេងទី៣(អាស្រ័យលើកម្ពស់របស់ក្មេង)
5. ឱ្យឈរជិតក្មេងទាំង ២នាក់ខាងលើតាមលំដាប់លំដោយនៃកម្ពស់។
6. រួចសួរទៅកាន់ក្មេងៗឯទៀតថា៖ តើកូនទី៣ មានកម្ពស់ខ្ពស់ជាង ឬ ទាបជាងកូនទាំង២?។
7. ជ្រើសរើសក្មេងទី ៤(អាស្រ័យលើកម្ពស់របស់ក្មេង)។
8. ឱ្យឈរជិតក្មេងទាំង ៣នាក់ខាងលើតាមលំដាប់លំដោយនៃកម្ពស់។
9. រួចសួរទៅកាន់ក្មេងៗឯទៀតថា៖ តើកូនទី៤ មានកម្ពស់ខ្ពស់ជាង ឬ ទាបជាងកូនទាំង៣?។
10. បន្តអនុវត្តរហូតដល់អស់ក្មេង ដោយតម្រង់ជួរទៅតាមលំដាប់លំដោយនៃកម្ពស់ ពីទាបទៅខ្ពស់ និងពីខ្ពស់ទៅទាប។